**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអភិវឌ្ឍន៍ជនបទ**
នាយកដ្ឋានផែនការ និងទំនាក់ទំនងសាធារណៈ
លេខៈ ០៤១/២០ ន.ផ.ទ./ក.អ.ជ

ថ្ងៃសុក្រ ១២ កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែកក្កដា ឆ្នាំ២០២០

**សូមគោរពជូន**
**ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ**

**កម្មវត្ថុ** ÷ របាយការណ៍វឌ្ឍនភាពការងារប្រចាំខែមិថុនា ឆ្នាំ២០២០ របស់នាយកដ្ឋានផែនការ និងទំនាក់ទំនងសាធារណៈ ។

សូមគោរពជម្រាបជូន **ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី** មេត្តាជ្រាបអំពីរបាយការណ៍វឌ្ឍនភាពការងារប្រចាំខែមិថុនា ឆ្នាំ២០២០ របស់នាយកដ្ឋានផែនការ និងទំនាក់ទំនងសាធារណៈដូចខាងក្រោម៖

## ១. ស្ថានភាពមន្ត្រីរាជការ

- ចំនួនមន្ត្រីរាជការសរុប ៤៧ នាក់ ស្ត្រី ១១ នាក់(ក្នុងនោះមន្ត្រីជាប់កិច្ចសន្យា ០១ រូប )
- ដឹកនាំដោយប្រធាននាយកដ្ឋាន ០១ រូប និងអនុប្រធាន ០៧ រូប (ស្ត្រី០២រូប)
- មន្ត្រីសហការជាមួយគម្រោងមានដូចខាងក្រោម៖

| ល.រ | ឈ្មោះ | ភេទ | មុខងារ | គម្រោងកម្មវិធី |
|---|---|---|---|---|
| ១ | ស្រ៊ន់ ពិធូ | ប | អនុប្រធាននាយកដ្ឋាន | គម្រោង TSLDP និង RRIP |
| ២ | ទាង ឆាយហៀង | ប | អនុប្រធាននាយកដ្ឋាន | គម្រោង CSADRMP |
| ៣ | នួន មុនីចិន្តា | ស | អនុប្រធាននាយកដ្ឋាន | គម្រោង IFAD |
| ៤ | សួស បូរិន្ទសក្តិ | ប | ប្រធានការិយាល័យ | កម្មវិធីហេដ្ឋារចនាសម្ព័ន្ធជនបទ RIP III |
| ៥ | ហេង ស្រីស្រស់ | ស | ប្រធានការិយាល័យ | គម្រោង CSADRMP |
| ៦ | ហ៊ឹម សួរជាតិ | ប | អនុប្រធានការិយាល័យ | កម្មវិធីហេដ្ឋារចនាសម្ព័ន្ធជនបទ RIP III |
| ៧ | គង់ សោភា | ស | អនុប្រធានការិយាល័យ | គម្រោង CSADRMP |

## ២. របាយការណ៍សម្រាប់ថ្នាក់ដឹកនាំនាយកដ្ឋាន

- រៀបចំ និងសម្របសម្រួលការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ឆ្នាំ២០២១-២០២៣ និងផែនការថវិកាកម្មវិធីឆ្នាំ២០២១ របស់ក្រសួងអភិវឌ្ឍន៍ជនបទ ជាមួយនាយកដ្ឋានជំនាញ និងមន្ទីរ អភិវឌ្ឍន៍ជនបទ រាជធានី-ខេត្តទាំង ២៥ តាមរយៈប្រព័ន្ធអនឡាញ
- បញ្ចប់ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២១-២០២៣ របស់ក្រសួងដោយបាន

បញ្ចូលគម្រោងវិនិយោគសាធារណៈបីឆ្នាំរំកិល គម្រោងវិនិយោគឋវិការដ្ឋ គម្រោងវិនិយោគហិរញ្ញប្បទានដៃគូ បញ្ហាភាពក្រីក្រ និងយេនឌ័រចូលក្នុងផែនការយុទ្ធសាស្ត្រថវិកាបីឆ្នាំរំកិល

- រៀបចំរបាយការណ៍សមិទ្ធកម្មថវិកាកម្មវិធីប្រចាំឆមាសទី១ ឆ្នាំ២០២០
- បន្តរៀបចំ និងធ្វើបច្ចុប្បន្នភាពផែនការថវិកាឆ្នាំ ២០២១ របស់ក្រសួងដើម្បីត្រៀមលក្ខណៈចូលរួមចរចាកញ្ចប់ថវិកាប្រចាំឆ្នាំជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ចូលរួមប្រជុំត្រួតពិនិត្យ និងវាយតម្លៃរបាយការណ៍អនុវត្តកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។
- កំពុងរៀបចំសេចក្តីព្រាងគោលនយោបាយជាតិអភិវឌ្ឍន៍ជនបទឆ្នាំ២០២១-២០៣០ ។

## ៣. សកម្មភាពការងារជំនាញ ការិយាល័យជំនាញទាំង ០៥ មានសកម្មភាពដូចខាងក្រោម ៖

### ៣.១ ការិយាល័យកិច្ចការទូទៅ

- បានទទួលលិខិតចូលទូទៅចំនួន ០៨ ច្បាប់
- បានទទួលលិខិតចូលក្នុងអង្គភាពចំនួន ០៤ ច្បាប់
- បានទទួលចូលក្រៅក្រសួងចំនួន ០៤ ច្បាប់
- លិខិតចេញទូទៅចំនួន ០៨ ច្បាប់
- លិខិតបញ្ជូនចំនួន ០១ ច្បាប់
- លិខិតបេសកកម្មចំនួន ០១ ច្បាប់
- លិខិតអញ្ជើញចំនួន ០១ ច្បាប់
- លិខិតបង្គាប់ការចំនួន ០០ ច្បាប់
- លិខិតសុំច្បាប់ចំនួន ០០ ច្បាប់
- លិខិតប្រកាសចំនួន ០០ ច្បាប់
- គ្រប់គ្រងវត្តមានប្រចាំខែរបស់មន្ត្រីរាជការ ។

### ៣.២ ការិយាល័យផែនការ និងស្ថិតិ

- រៀបចំ និងសម្របសម្រួលការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ឆ្នាំ២០២១-២០២៣ របស់ក្រសួងអភិវឌ្ឍន៍ជនបទ ជាមួយនាយកដ្ឋានជំនាញ និងមន្ទីរអភិវឌ្ឍន៍ជនបទ រាជធានី-ខេត្តទាំង ២៥
- រៀបចំ និងសម្របសម្រួលការរៀបចំផែនការថវិកាកម្មវិធីឆ្នាំ ២០២១ របស់ក្រសួងអភិវឌ្ឍន៍ជនបទ ជាមួយនាយកដ្ឋានជំនាញ និងមន្ទីរអភិវឌ្ឍន៍ជនបទ រាជធានី-ខេត្តទាំង ២៥
- ចូលរួមកិច្ចប្រជុំអន្តរក្រសួងកម្រិតនយោបាយ ដើម្បីពិនិត្យ និងផ្តល់ការឯកភាពលើសេចក្តីព្រាងរបាយការណ៍វឌ្ឍនភាពឆ្នាំ២០១៩ នៃការសម្រេចបានគោលដៅអភិវឌ្ឍប្រកប

ដោយចីរភាពកម្ពុជា ២០១៦-២០៣០ នៅសណ្ឋាគារភ្នំពេញ រាជធានីភ្នំពេញ
- ចូលរួមកិច្ចប្រជុំក្រុមការងារតាក់តែងសមិទ្ធផល បញ្ហាប្រឈម ព័ត៌មាន ទិន្នន័យ វិធីសាស្ត្រ យន្តការគណនា និងប្រើប្រាស់ធនធាន "កសពជ" នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ
- ចូលរួមពិភាក្សាលើការធ្វើសមាហរណកម្មការរៀបចំថវិកាចរន្ត និងវិនិយោគនៅក្នុងក្របខ័ណ្ឌច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ចូលរួមកិច្ចប្រជុំលើកទី១ របស់គណៈកម្មាធិការដឹកនាំការងាររៀបចំគោលនយោបាយជាតិអភិវឌ្ឍន៍ជនបទ (គរគ) នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ
- ចូលរួមកិច្ចប្រជុំផ្ទៃក្នុងនាយកដ្ឋាន នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ ។

## ៣.៣ ការិយាល័យតាមដាន និងវាយតម្លៃ

- ពិនិត្យ និងប្រមូលរបាយការណ៍សមិទ្ធកម្មស្តីពីលទ្ធផលក្នុងការអនុវត្តថវិកាកម្មវិធីក្នុងឆមាសទី១ ឆ្នាំ២០២០ និងចុះបេសកម្មទៅខេត្តកំពង់ធំ និងខេត្តព្រះវិហារ ។

## ៣.៤ ការិយាល័យបច្ចេកវិទ្យាព័ត៌មាន

- ត្រួតពិនិត្យម៉ាស៊ីន Printer ចំនួន ១០ ដង
- ត្រួតពិនិត្យប្រព័ន្ធ Internet ចំនួន ០៨ ដង
- តម្លើងកម្មវិធី Ms. Office ចំនួន ១២ ដង
- ជួសជុលកុំព្យូទ័រ ចំនួន ១៣ ដង
- ធ្វើបច្ចុប្បន្នភាពប្រព័ន្ធគ្រប់គ្រងមូលដ្ឋានទិន្នន័យផ្លូវជនបទ
- ធ្វើបច្ចុប្បន្នភាពប្រព័ន្ធគ្រប់គ្រងទិន្នន័យមន្ត្រីរាជការ
- បញ្ចូលទិន្នន័យក្នុងគេហទំព័រផេកនាយកដ្ឋាន
- ធ្វើបច្ចុប្បន្នភាពគេហទំព័រក្រសួងអភិវឌ្ឍន៍ជនបទ ។

## ៣.៥ ការិយាល័យអាស៊ាន និងសហប្រតិបត្តិការអន្តរជាតិ

- បានផ្តល់សំណើសុំអន្តរាគមន៍ ដើម្បីសុំចុះបញ្ជីស្លាកលេខ ONG សម្រាប់រថយន្ត និងទោចក្រយានចំនួន ០៤គ្រឿង របស់អង្គការ ActionAid International Cambodia និងអង្គការ World Vision
- បានផ្តល់សំណើសុំហត្ថលេខាលើកិច្ចព្រមព្រៀងសហប្រតិបត្តិការរវាងក្រសួងអភិវឌ្ឍន៍ជនបទ និងអង្គការ RDI
- ប្រមូលរបាយការណ៍ត្រីមាសទី២ និងឆមាសទី១ ឆ្នាំ២០២០ របស់អង្គការមិនមែនរដ្ឋាភិបាល ដើម្បីបញ្ចូលទៅក្នុងរបាយការណ៍ប្រចាំឆមាសទី១ របស់ក្រសួង
- បានចុះពិនិត្យសមិទ្ធផលការងាររបស់អង្គការមិនមែនរដ្ឋាភិបាលនៅក្នុងខេត្តកំពង់ធំ សៀមរាប និងខេត្តបន្ទាយមានជ័យ ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី** មេត្តាជ្រាបជារបាយការណ៍ដោយក្តីអនុគ្រោះ ។

សូម **ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំ ។

អ្នកធ្វើរបាយការណ៍

**គុន សុវណ្ណារ័ត្ន**

បានឃើញ និង ឯកភាព

សូមគោរពជូន **ឯកឧត្តមរដ្ឋលេខាធិការ** មេត្តាជ្រាបជារបាយការណ៍ដ៏ខ្ពង់ខ្ពស់។

**ប្រធាននាយកដ្ឋាន**

**ម៉ា សុវណ្ណា**

ថ្ងៃ អង្គារ ៨ កើត ខែ ស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែ កក្កដា ឆ្នាំ២០២០

**បានឃើញ និងឯកភាព**

សូមគោរពជូន **ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី** មេត្តាជ្រាបជារបាយការណ៍ដ៏ខ្ពង់ខ្ពស់។

**រដ្ឋលេខាធិការ**

**សុខ_សារាវុឌ្ឍ**

28-07-2020

ចម្លងជូនៈ
- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រី
- ឯកឧត្តមរដ្ឋលេខាធិការទទួលបន្ទុក
- ឯកឧត្តមអនុរដ្ឋលេខាទទួលបន្ទុក
- ឯកឧត្តមអគ្គនាយក

"ដើម្បីជូនជ្រាប
- ឯកសារ-កាលប្បវត្តិ